គណបក្ស សម រង្សី

SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

- បានឃើញលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
- បានឃើញសេចក្តីសំរេចលេខ ៤៣៨ សសរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០០ ស្តីពីការកំណត់បទវិនិយរបស់គណបក្ស សម រង្សី
- បានឃើញលិខិតរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ (**NDI**) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៥ ផ្ញើជូនអគ្គលេខាធិការគណបក្ស សម រង្សី ស្តីពីការថ្លែងរបស់លោក ខឹម វ៉ាសនា នៅក្នុងវេទិកា **NDI** ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥
- បានឃើញសេចក្តីថ្លែងការណ៍របស់លោកប្រធាន សម រង្សី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការថ្កោលទោសអាកប្បកិរិយាទាំងឡាយដែលមានបំណងបំបែកបំបាក់ជាតិ
- បានឃើញលិខិតលេខពិសេស ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ របស់លោកប្រធានគណបក្សស្តីទី គង់ គាំ ផ្ញើជូនលោក ខឹម វ៉ាសនា
- បានឃើញសេចក្តីសំរេចលេខ ០១ ក្រវ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៥ របស់ក្រុមប្រឹក្សាវិនិយ និងដោះស្រាយវិវាទរបស់គណបក្ស

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សបានបើកកិច្ចប្រជុំពិសេស នៅវេលាម៉ោង ១១ និង៣០នាទី ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៥ បានសំរេចដូចតទៅ :

១_ ថ្កោលទោសលោក ខឹម វ៉ាសនា ដែលបានធ្វើសកម្មភាពមានចរិតបំបែកបំបាក់ជាតិ និងមានអាកប្បកិរិយាប្រមាថដោយផ្ទាល់ និងដោយប្រយោល ដល់ប្រជាពលរដ្ឋខ្មែរ និងអង្គព្រះមហាក្សត្រ ដែលផ្ទុយពីគោលនយោបាយរបស់គណបក្ស ។

២_ ព្យួរតំណែងសមាជិកគណៈកម្មាធិការនាយករបស់លោក ខឹម វ៉ាសនា ហើយបញ្ឈប់លោក ខឹម វ៉ាសនា មិនឲ្យចូលរួមក្នុងវេទិកាសាធារណៈនានា ក្នុងនាមគណបក្ស សម រង្សី ។

៣_ ដាក់សំណុំរឿង និងឯកសារពាក់ព័ន្ធករណីលោក ខឹម វ៉ាសនា នេះ សំរាប់កិច្ចប្រជុំពេញអង្គរបស់គណៈកម្មាធិការនាយកគណបក្ស នាពេលខាងមុខ ដើម្បីពិនិត្យពិភាក្សា និងវិនិច្ឆ័យ ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
E-mail address : srphqpp@forum.org.kh, cabinet@samrainsyparty.org